# ចម្លាក់នាគរាជខ្មែរនៅស.វ.ទី៧-៨

នាគរាជ (Nãgarãja) ឬស្តេចនាគ នៅក្នុងអត្ថបទនេះសំដៅលើចម្លាក់នៅតាមប្រាសាទខ្មែរនៅស.វ.ទី៧-៨ មានរាងកាយក្នុងទម្រង់ដូចមនុស្ស និងប្រក់នាគនៅខាងលើព្រះសិរ។ ក្នុងទេវកថាព្រហ្មញ្ញសាសនា នាគរាជត្រូវជាកូនរបស់ឥសីកស្យាប និងនាងកាទ្រុ ដែលមានបងប្អូនចំនួន ១០០០នាក់។[១] ក្នុងនោះ មាននាគរាជចំនួនបីសំខាន់ៗដែលគេស្គាល់ច្រើនជាងនៅក្នុងទេវកថាមាន អនន្ត, វាសុកិ និងតក្សក។ អនន្ត (Ananta) ឬ សេស (Shesha) គឺជាតួអង្គនាគដែលគេស្គាល់ថាជានាគដែលព្រះវិស្ណុផ្ទុំនៅពីលើវង់ចាំបង្កើតលោក និងជាបងប្រុសច្បងក្នុងចំណោមនាគរាជទាំងបី។[២] នាគរាជទីពីរឈ្មោះថា "វាសុកិ" (Vãsuki) ជាតួអង្គនាគដែលគេស្គាល់ជាគ្រឿងអលង្ការរបស់ព្រះឥសូរពាក់ជាប់នឹងករបស់ទ្រង់ និងជានាគដែលយកធ្វើជាខ្សែសម្រាប់ការកួរសមុទ្រទឹកដោះយកទឹកអម្រឹត ដែលអ្នកកួរម្ខាងជាទេវតា និងម្ខាងទៀតជាអសុរ។[៣] នាគរាជទីបីឈ្មោះថា "តក្សក" (Takshaka) គឺជាតួអង្គនាគដែលគេស្គាល់ថាជាអ្នកគ្រប់គ្រងព្រៃខន្ទវ (Khandava) ដែលដុតដោយអជ៌ន និងជាតួអង្គដែលសម្លាប់ចៅប្រុសរបស់អជ៌នឈ្មោះ បរិក្សិត (Parikshit) នៅក្នុងរឿងមហាភារត។[៤] នាគ គឺជាសេនាការពារទ្រព្យសម្បត្តិទាំងពួងនៃផែនដី ហើយជាអ្នកថែរក្សាថាមពលនៅក្នុងទឹក ឬជាសត្វតំណាងឲ្យទឹក ឬភាពត្រជាក់ត្រជុំ។[៥]

នៅក្នុងសិល្បៈឥណ្ឌាបុរាណ ចម្លាក់នាគរាជ គេនិយមឆ្លាក់ខ្លាំងណាស់ ហើយជួនកាលមានឆ្លាក់ជាបដិមាទោលទៀតផង (រូបលេខ១)។ ចំណែក នៅក្នុងសិល្បៈខ្មែរនៅស.វ.ទី៧-៨ គេមិនដែលប្រទះឃើញបដិមាទោលនាគរាជដូចនៅឥណ្ឌាឡើយ ហើយចម្លាក់នាគរាជភាគច្រើនគេឆ្លាក់នៅលើផ្តែរទ្វារ និងខ្លះឆ្លាក់នៅតាមសសរផ្តោបនៃប្រាសាទ។ ជាការកត់សម្គាល់ ចម្លាក់នៅលើផ្តែរទ្វារមានយ៉ាងតិច ៦ ផ្ទាំង គឺផ្តែរទ្វារខាងកើតប្រាសាទយាយព័ន្ធ (S1) ក្នុងតំបន់ប្រាសាទសំបូរព្រៃគុក (ខេត្តកំពង់ធំ) ផ្តែរទ្វារប្រាសាទព្រះធាតុរកា (ខេត្តកំពង់ធំ) ផ្តែរទ្វាររកឃើញនៅវត្តសូភាស (ខេត្តកំពង់ចាម) ផ្តែរទ្វាររកឃើញនៅវត្តតាំងស្រែ (ខេត្តកំពង់ចាម) ផ្តែរទ្វារប្រាសាទព្រៃក្មេង (ខេត្តសៀមរាប) និងផ្តែរទ្វារមួយមិនស្គាល់ប្រភពរក្សាទុកនៅសារមន្ទីរខេត្តកំពង់ធំ។ នៅលើផ្តែរទ្វារ

---

[១] Vettam 1975.

[២] Bénisti 1965.

[៣] Thomas 1999.

[៤] Rodeda 2005.

[៥] Roveda 2005.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ខាងកើតប្រាសាទយាយព័ន្ធ[៦] គេឆ្លាក់រូបនាគរាជនៅខាងស្តាំព្រះឥន្ទ្រ ក្នុងកាយវិការយកព្រះហស្ត ទាំងពីរដាក់ខ្វែងគ្នាមកប៉ះត្រង់ដើមដៃ ដែលមើលទៅទំនងកំពុងគោរពដល់ព្រះឥន្ទ្រាធិរាជដែល ជាស្តេចនៅស្ថានសួគ៌ (រូបលេខ២២)។ ផ្តែរទ្វារប្រាសាទព្រៃក្មេងដែលសព្វថ្ងៃរក្សាទុកនៅសារមន្ទីរហ្គីមេ ប្រទេសបារាំង[៧] (រូបលេខ២៣) និងផ្តែរទ្វារមិនស្គាល់ប្រភពរកឃើញនៅសារមន្ទីរខេត្តកំពង់ធំ[៨] (រូបលេខ២៤) គេឆ្លាក់រូបនាគរាជជិះលើសត្វមករទាំងសងខាងដូចគ្នា ដែលជាទូទៅនាគក៏តំណាង ឱ្យទឹក រីឯសត្វមករក៏ជាសត្វទេវកថាតំណាងឱ្យទឹកដូចគ្នា។ ផ្តែរទ្វារខាងត្បូងប្រាសាទព្រះធាតុរកា វិញ[៩] (រូបលេខ២៥) គេឆ្លាក់រូបនាគរាជនៅសងខាងផ្តែរ ក្នុងលក្ខណៈជាតួអង្គទោលអង្គុយបញ្ឈរ ជង្គង់ម្ខាង និងព្រះហស្តទាំងពីរលើកប្រណម្យដល់តួអង្គនៅចំពាក់កណ្តាលផ្តែរដែលជាព្រះឥន្ទ្រ ដែលមានអត្ថន័យស្រដៀងនឹងចម្លាក់នៅប្រាសាទយាយព័ន្ធដែរ។ ផ្តែរទ្វារនៅវត្តសូភាសវិញ (រូបលេខ២៦) គេឆ្លាក់រូបនាគរាជនៅអមសងខាងព្រះឥន្ទ្រ ក្នុងកាយវិការលើកដៃប្រណម ដែលមានលក្ខណៈ ស្រដៀងទៅនឹងផ្តែរទ្វារប្រាសាទព្រះធាតុរកាដែរ។ ផ្តែរទ្វារចុងក្រោយដែលរកឃើញនៅវត្តតាំង ស្រែ (រូបលេខ២៧) មានលក្ខណៈប្លែកពីផ្តែរទ្វារដែលបានរៀបរាប់ទាំងអម្បាលម៉ានខាងលើ ដ្បិតគេ ឆ្លាក់រូបនាគរាជនៅខាងព្រះបាទរបស់ព្រះវិស្ណុ ក្នុងរឿងព្រះវិស្ណុផ្ទុំលើនាគអនន្តរង់ចាំបង្កើតលោក។ ការឆ្លាក់រូបនាគរាជ (ស្តេចនាគ) នៅខាងចុងព្រះបាទរបស់ព្រះវិស្ណុ គឺជាទម្រង់មួយដែលចម្លាក់ ព្រះវិស្ណុផ្ទុំនៅស.វ.ទី៧ដូចគ្នាពុំឃើញមានឡើយ ហើយចម្លាក់នេះទំនងតំណាងឱ្យទឹកសមុទ្រ ដ្បិតនាគតំណាងឱ្យទឹក ដែលខុសពីផ្តែរផ្សេងៗទៀតយើងឃើញគេឆ្លាក់ជារូបរលក និងរូបក្បាល សត្វមករនៅក្បែរព្រះកាយព្រះវិស្ណុដែលបញ្ជាក់ពីទឹកដូចគ្នា។

ក្រៅពីចម្លាក់នៅលើផ្តែរដែលបានរៀបរាប់ខាងលើ មានចម្លាក់ឥដ្ឋដែលគួរឱ្យសម្គាល់មួយ ទៀតនៅប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង (ស.វ.ទី៨) ដែលគេឆ្លាក់នៅតាមជើងសសរផ្តោបរបស់ ប្រាសាទ ហើយយើងឃើញមានចំនួនបីកន្លែង (រូបលេខ២៨)។ ចម្លាក់នីមួយៗអង្គុយក្នុងទម្រង់ មហារាជលីលាសន (Mahãrãjalīlãsana) ដោយបញ្ឈរជង្គង់ឆ្វេងឡើងលើ ម្ខាងទៀតដាក់រាបស្មើ ព្រះហស្តស្តាំដាក់ច្រត់លើក្បាលជង្គង់ និងព្រះហស្តឆ្វេងយកកែងដាក់ច្រត់លើក្បាលជង្គង់ឆ្វេង។ ទម្រង់នេះហាក់បីដូចជាទ្វារបាលរបស់ប្រាសាទដូច្នេះដែរ ព្រោះយើងដឹងហើយថានាគតំណាង ឱ្យភាពត្រជាក់ត្រជុំ និងជាតួអង្គម្នាក់ក្នុងលោកធាតុទាំងប្រាំនៃភ្នំព្រះសុមេរុដែលជាស្នូលនៃផែនដី

[៦] Bénisti 1977.

[៧] Baptiste and Zéphir 2008.

[៨] Bénisti 1974.

[៩] Ben 2005.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

(នាគ គ្រុឌ រក្សស យក្ស និងមហារាជ)[៩] ម៉្លោះហើយទើបយើងឃើញនៅសម័យក្រោយៗគេនិយមឆ្លាក់បង្កាន់ដៃនាគនៅតាមផ្លូវចូលប្រាសាទ។

ជារួមមក ចម្លាក់នាគរាជដែលបានបង្ហាញខាងលើ ជាតឹកតាងមួយដែលឱ្យយើងដឹងថា ខ្មែរជ្រួតជ្រាបនូវលទ្ធិព្រហ្មញ្ញសាសនាយ៉ាងខ្លាំងក្លា ម៉្លោះហើយទើបបានជាមានចម្លាក់ទេវកថាទាំងនេះឡើងនៅតាមប្រាសាទខ្មែរនៅស.វ.ទី៧-៨។ តួអង្គនាគរាជដែលបានរៀបរាប់ទាំងអម្បាលម៉ាន យើងពុំអាចដឹងថាតើជាតួអង្គនាគមួយណា ឬឈ្មោះអ្វីបានឡើយ ព្រោះដូចយើងបានបញ្ជាក់ខាងដើមថា នៅក្នុងលទ្ធិព្រហ្មញ្ញសាសនា គេយល់ថានាគរាជមានបងប្អូនចំនួន ១០០០នាក់ តែក្នុងនោះមានបីដែលស្គាល់ច្រើន៕

## ឯកសារយោង


**Baptiste, P. and Zéphir, T.**

2008, *'L'art Khmer dans les collections du musée Guimet'* Paris.

**Ben, W.**

2015, *Riders on the Storms, Pre-Angkorian Indra Lintel Imagery Kinship and the Monsoon,* 15th EurASEAA International Conference 6 – 10 July, 2015, Université Paris Ouest Nanterre la Défense.

**Bénisti, M.**

1965, 'Répresentations Khmères de Viśṇu couché' in *Art Asiatiques*, Tome 11, Paris.

1974, Recherches sur le premier art khmer, VI. Linteaux inéits et linteaux méconnus, *Art Asiatique*, Tome 30, Paris

1977, Recherches sur le premier art khmer, VII. 'Le problème de Sambor S.1', *Art Asiatique*, Tome 33, Paris

**Glaize, M.**

2009, *'Les monument du group d'Angkor'* Paris.

**Roveda, V.**

2005, *'Image of the gods',* Bangkok

**Thomas, P.**

1999, *'Epics, Myths and Legends of India'*, Treasure House of Books, Boombay.

**Vettam, M.**

1999, 'Kadru', *Puranic encyclopedia: a comprehensive dictionary with special reference to Epic and Puranic literature*, Delhi.


[៩] Glaize 2009.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ រូបនាគរាជក្នុងទម្រង់ជាទ្វារបាលនៃសិល្បៈឥណ្ឌាបុរាណ ស.វ.ទី៩ (តាំងនៅសារមន្ទីរ V & A, London)



រូបលេខ២៖ ផ្តែរប្រាសាទយាយព័ន្ធ តំបន់ប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ



រូបលេខ៣៖ ផ្តែរប្រាសាទព្រៃក្មេង ខេត្តសៀមរាប សព្វថ្ងៃនៅសារមន្ទីរហ្គីមេ ប្រទេសបារាំង (រូបថត៖ លាក់ ស៊ីផាន់ណា)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៤៖ ផ្ដែរមិនស្គាល់ប្រភពនៅសារមន្ទីរខេត្តកំពង់ធំ (រូបថត៖ លួន ទីឃា)



រូបលេខ២៥៖ ផ្ដែរប្រាសាទព្រះធាតុរកា ខេត្តកំពង់ធំ



រូបលេខ២៦៖ ផ្ដែររកឃើញនៅវត្តសូភាស ខេត្តកំពង់ចាម (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ ផ្តែររកឃើញនៅវត្តតាំងស្រែ ខេត្តកំពង់ចាម (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ៨៖ ចម្លាក់នាគរាជឆ្លាក់នៅជើងសសរផ្តោបនៅប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង (រូបថត៖ លឿង សុវណ្ណ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី